154 BOTUM OUK

long beach unified school district

# CAMBODIAN LEGENDS

# រឿងព្រេងខ្មែរ





## JUDGE RABBIT STORIES

## រឿង សុភាទន្សាយ

## សប់គ្រួស.ខ្មែរ

ENGLISH / CAMBODIAN

South East Asian Learners Project

S. E. A. L.

LONG BEACH UNIFIED SCHOOL DISTRICT
Education Department
701 Locust Avenue, Long Beach
VERNON A. HINZE, Superintendent

long beach unified school district

OFFICE OF CONSULTANT, FOREIGN LANGUAGE, ESL, BILINGUAL-BICULTURAL AND INDIAN EDUCATION

* * * * * * * * * * * * * * * * *

SOUTH EAST ASIAN LEARNERS PROJECT

(S. E. A. L.)

* * * * * * * *

# CAMBODIAN LEGENDS

## ENGLISH - CAMBODIAN

Prepared by:

Chandha SAU
Bettie Lou SECHRIST
Kry LAY

Under the supervision of:
Betty H. SEAL
Consultant. ESL. Bilingual-Bicultural Education

SUMMER 1978

PREFACE

Nowadays, stories and legends are seen on television, in magazines and in legend books from various countries around the world, and heard on radio. Along with these, the Long Beach Unified School District, through the Southeast Asian Learners Project, has collected and composed this booklet of legends from Cambodia.

We hope that the booklet will be a good friend for readers in many ways: it will help readers to gain knowledge of English and Cambodian; the legends can be told to friends in leisure time; the meaning of the stories can instruct good conduct. These legends are very popular in Cambodia.

We have tried to remain true to the traditional forms of these stories as far as possible, and we apologize for any possible discrepancies.

អារម្ភកថា

នាបច្ចុប្បន្ននេះ យើងបានឮ បានឃើញ រឿងរ៉ាវជាច្រើនតាមទូរទស្សន៍ វិទ្យុ ទស្សនាវដ្ដី និង សៀវភៅរឿងព្រេងពីប្រទេសផ្សេងៗ ក្នុងពិភពលោក ។ ជាមួយគ្នានោះ ក្រសួងអប់រំជាតិ តាមរយៈផែនការអប់រំជនជាតិអាស៊ីអាគ្នេយ៍ បានប្រមូលរឿងព្រេងមកនិពន្ធឡើងទៅជាកូនសៀវភៅនេះឡើង ។

យើងសង្ឃឹមថា កូនសៀវភៅនេះនឹងបានទៅជាមិត្តល្អដល់អ្នកអានច្រើនយ៉ាង គឺ ជួយអ្នកអានឲ្យបានចេះភាសាខ្មែរ និង អង់គ្លេស ឲ្យបានចេះចាំរឿងនេះនិទានប្រាប់មិត្ត នៅពេលកំសាន្តលំហែជាមួយគ្នា និងឲ្យបានជាគតិលើរាល់ជីវិតផ្ទាល់ខ្លួន ឬ ញាតិមិត្តផងដែរ ។ រឿងព្រេងកូនសៀវភៅនេះ ជារឿងមានប្រជាប្រិយភាពក្នុងស្រុកខ្មែរ ។

យើងព្យាយាមរក្សាទុកនូវលំនាំរឿងព្រេងនេះ តាមប្រពៃណីយ៉ាងអស់ពីចិត្ត ប៉ុន្តែប្រសិនបើមានការឆ្គាំឆ្គងពីចំណោះលោកលេខ្យុរណាមួយ យើងសូមអភ័យទោសទុកជាមុន ។

# TABLE OF CONTENTS

Page
2. How Judge Rabbit Helped Elephant
សុភាទន្សាយជួយជីវិតដំរី
4. How Judge Rabbit Was Trapped and Tried to Escape
សុភាទន្សាយជាប់អន្ទាក់ រកមធ្យោបាយដោះខ្លួន
6. How Judge Rabbit Got Across the River
សុភាទន្សាយឆ្លងស្ទឹង
8. Judge Rabbit and the Old Lady
សុភាទន្សាយ និង ដូនចាស់
10. Judge Rabbit, the Tiger, and the Men
សុភាទន្សាយ ខ្លា និង អ្នកស្រុក
12. How Judge Rabbit Made Friends With the Goat
សុភាទន្សាយ និង ពពែ
14. How Judge Rabbit Helped His Friend the Goat
សុភាទន្សាយជួយជីវិតពពែ
18. Judge Rabbit and the Snail Race
សុភាទន្សាយ និង ខ្យង
22. How Judge Rabbit Saved Men From the Tiger
សុភាទន្សាយជួយជីវិតឈ្មួញលំពាយ បួននាក់
24. How Judge Rabbit Escaped Once More From the Tiger
សុភាទន្សាយរត់ដោះខ្លួនពីខ្លាម្ដងទៀត
28. How Judge Rabbit Saved a Man and Punished a Crocodile
សុភាទន្សាយជួយមនុស្សឲ្យរួចពីក្រពើ ហើយដាក់ទោសទណ្ឌដល់ក្រពើ
32. How Judge Rabbit Captured the Ghost
សុភាទន្សាយបោកខ្មោចបញ្ចូលដប

## HOW JUDGE RABBIT HELPED ELEPHANT

One day Judge Rabbit went for a walk in the forest. He met Elephant. Judge Rabbit exclaimed, "Oh, Brother Elephant, you seem sad. You are sad, aren't you? What's the matter?"

The elephant responded, "Brother, I am very sad. Yesterday, I met a tiger. The tiger wanted to eat me. That's why I am so sad. I am afraid. I don't know what to do!"

The rabbit responded, "That's no problem at all. Wait, I will protect you from that."

After hearing that, the elephant was very happy and said, "I am going to do what you want me to do, my Brother."

Judge Rabbit replied, "Come and see me tomorrow. Listen to me, don't be afraid, OK?"

The next day, Elephant came to meet Judge Rabbit. The rabbit climbed up and sat on the back of the elephant. He held a bamboo cane in his hand and said to the elephant, "When I give you a sign to the left, you must turn your head to the left. When I give you a sign to the right, you must turn right."

The elephant agreed.

Then the tiger appeared for water. Judge Rabbit pretended not to see the tiger. At the same time, he rode and commanded the elephant to turn left or right with the bamboo stick. The elephant followed strictly.

The tiger was shocked and stared at the sight and thought, "Why, how can such a little animal as that be the master of such a great animal and not be eaten by the great one?"

The tiger watched in wonder. Finally he became frightened and ran to the safety of the forest. Elephant was safe and sound thanks to the intelligence of Judge Rabbit.

# សុភាទន្សាយជួយជីវិតដំរី

ថ្ងៃមួយ សុភាទន្សាយដើរលេងកំសាន្តក្នុងព្រៃ ប្រទះឃើញសត្វដំរី ក៏ស្រែកសួរថា : នែបងដំរី បងឯងតាក់ស្លុតជាព្រួយ បងឯងមានរឿងអ្វី ឬ ដំរីឆ្លើយថា : បងទន្សាយអើយខ្ញុំព្រួយចិត្តណាស់ ម្សិលមិញខ្ញុំបានជួបខ្លាមួយ វាប្រាប់ខ្ញុំថា វាចង់ស៊ីសាច់ខ្ញុំ ខ្ញុំភ័យណាស់ ខ្ញុំមិនដឹងជាគិតយ៉ាងណាទេ
ទន្សាយតបថា : គ្រាន់តែបញ្ហានេះមានការអ្វីត្រូវព្រួយ ចាំខ្ញុំជួយបងឯងឲ្យរួចខ្លួន ។ ឮដូច្នោះ ដំរីអរណាស់ហើយតបថា : ខ្ញុំនឹងធ្វើតាមបងឯងទាំងអស់ បងឯងឲ្យខ្ញុំធ្វើអ្វីក៏ខ្ញុំធ្វើដែរ ។
ទន្សាយតបថា : ស្អែកមកជួបខ្ញុំ ហើយបងឯងកុំព្រួយឲ្យសោះ ឮទេ រួចទន្សាយក៏ចេញទៅ ។

ស្អែកឡើង ដំរីមកជួបទន្សាយដូចបានព្រោងទុក ទន្សាយឡើងលើខ្នងដំរី ដៃកាន់ដំបង ឬឈើ រួចនិយាយថា : កាលណាខ្ញុំគោះបងឯងខាងឆ្វេង បងឯងងាកឆ្វេង បើខ្ញុំគោះបងឯងខាងស្តាំ បងឯងងាកស្តាំ ដំរីយល់ព្រម ។ ពេលដែលខ្លាចេញមករកផឹកទឹក ទន្សាយធ្វើជាមិនឃើញខ្លា ក្នុងពេលជាមួយគ្នានោះ ទន្សាយបញ្ជាដំរីផង បញ្ជាឲ្យដំរីងាកឆ្វេងស្តាំផង ។ ដំរីធ្វើតាមបញ្ជាទាំងអស់ សត្វខ្លាយរភាំង សំឡឹងទៅរក រួចពិចារណាថា ហេតុអ្វីបានជាសត្វតូចមួយក្លាយទៅជាចៅហ្វាយសត្វធំ ដែលជាសត្វស៊ីខ្លួនបាន ។ ខ្លាឆ្ងល់យ៉ាងខ្លាំង ទីបញ្ចប់ វាមានការភ័យជាខ្លាំង រួចរំដោះខ្លួនចូលទៅក្នុងព្រៃព្រាក ។

ដំរីបានរួចខ្លួនពីស្លាប់ដោយសារប្រាជ្ញារបស់សុភាទន្សាយ ។

## HOW JUDGE RABBIT WAS TRAPPED AND TRIED TO ESCAPE

Judge Rabbit was happy to see that the elephant was safe. He ran into the garden of a farmer looking for something to eat. Because he was junping up and down with joy, he stepped in one of the farmer's traps and was caught. When the farmer reached home, he placed an "angrote"* over Judge Rabbit to keep him from running away.

Near the rabbit, there was a small jar containing lots of fish. Judge Rabbit searched his mind for a way to escape. Finally, he asked the fish, "Fish! Fish! Do you want to escape?"

The fish replied, "Yes. We want to very much, but we don't know how!"

Judge Rabbit said, "You have to work together and swim very hard in one direction, so that the water will upset the jar. Then you will be free. If you stay here, they will kill you."

Then the fish swam very hard together until the jar fell over and all the fish fled to the pond nearby. Judge Rabbit began to cry out, "Ho! Ho! The fish are fleeing! The fish are fleeing!"

The farmer became so excited, he grabbed the angrote and ran after the fish. Judge Rabbit ran free and tripped the farmer. The poor farmer, lying on the ground said, "Well! Nothing for me! The fish are free in the pond, and the rabbit is in the forest!"

The moral of the story is, "A bird in the hand is worth more than two in the bush."

* An angrote is a bottomless bamboo cage which Cambodians use to catch fish.

## លុភាទន្សាយជាប់អន្ទាក់ រកមធ្យោបាយដោះខ្លួន

លុភាទន្សាយសប្បាយចិត្តណាស់ដោយឃើញសេរីរួចខ្លួន វាលោតសេរីរួចបោលទៅក្នុងចំការបន្លែមួយដើម្បីរកស៊ី ។ ក្នុងចំការនោះ ម្ចាស់ចំការបានដាក់អន្ទាក់ជាច្រើនកន្លែង ។ ដោយរីករាយ និងគំនិតដែលខ្លួនគិតត្រូវពេក វាលោតចុះ លោតឡើងក្នុងចំការ ក៏ជាប់អន្ទាក់នៅទីនោះ ។ គាប់ជួនពេលនោះ ម្ចាស់ចំការដើរមកដល់ល្មម ។ ម្ចាស់ចំការត្រេកអរ និងចាប់បានទន្សាយ គាត់ក៏ដោះទន្សាយយួរមកផ្ទះ ក្រុកវាក្នុងអង្រុត ។ នៅថ្ងៃនោះម្ចាស់ចំការបានប្រឡាយ ត្រីមួយធុង ។

លុភាទន្សាយរកមធ្យោបាយដើម្បីដោះខ្លួនឲ្យរួចពីអន្ទាក់ មួយស្របក់ ក៏ស្រែកទៅរកត្រីនៅក្នុងធុង ថា "ត្រី ត្រី ត្រីឯងចង់រត់ពីនេះឲ្យរួចខ្លួនទេ" ត្រីឆ្លើយថា "យើងចង់ខ្លាំងណាស់ តែមិនដឹងធ្វើម្តេចឲ្យបានចេញរួច" ។ លុភាទន្សាយតបថា "ត្រីឯងទាំងអស់គ្នាត្រូវព្រួតដៃគ្នាបំរះឲ្យខ្លាំង ហើយពេលណាធុងទឹកដួលខ្ទាយ អ្នកឯងនាំគ្នាបំរះចូលក្នុងអូរទឹកនេះទៅ តែបើប្រសិនជាត្រីឯងត្រាំនៅទីនេះ គេនឹងយកទៅស្លា បំព្រុំជាមិនខាន ។

ពួកត្រីក៏នាំគ្នាបំរះយ៉ាងខ្លាំងនៅក្នុងធុងទឹក រហូតដល់ធុងដួលរបកទឹកខ្ទាយ ។ លុភាទន្សាយឃើញត្រីលួនបំរះជិតទៅដល់អូរ ក៏ស្រែកឡើង "ត្រីរត់រួចអស់ហើយ ត្រីរត់រួចអស់ហើយ" ។ ម្ចាស់ចំការគិតតែពីស្តាយត្រី មិនបានគិតដល់ទន្សាយក៏ទៅទាញអង្រុត ដែលក្រុកទន្សាយ យកទៅរុតត្រី ។ ទន្សាយរួចខ្លួនក៏រត់ចេញបុកជើងម្ចាស់ចំការ ពុំភ្លាត់ជើងដួលព្រោងព្រាត ។ ត្រីក៏លោតចូលក្នុងទឹកអស់ ចំណែកទន្សាយក៏ចេញចូលក្នុងគុម្ពោតព្រៃបាត់ទៅ ។

ត្រីក៏រួចទន្សាយក៏រួច ។
បក្សីមួយក្នុងដៃ ប្រសើរជាងបក្សីរ-
បីនៅលើដើមឈើ ។

# HOW JUDGE RABBIT GOT ACROSS THE RIVER

On the same day that he escaped from the farmer, Judge Rabbit wanted to go across the river, but, alone, he could not do it. He thought to himself, "I will use a trick to confuse the crocodile. Then, he will carry me across the river."

He went to the bank of the river and saw the head of the crocodile barely emerged from the water. Judge Rabbit said, "Oh! Brother Crocodile, there is no grass to eat on this bank. Please take pity on me! Help me go across the river. I know a place which has sweet grass and sweet mud and also sweet water. It's good. You will be happy with your family there."

The crocodile was happy and replied, "If you, my brother, had pity on me, you would want to direct me to the place where there is sweet water and sweet mud. I would be so happy I would never forget your kindness."

Judge Rabbit said, "That being the case, let's go."

The crocodile called Judge Rabbit to sit on his back. When he saw the wrinkled skin of the crocodile all covered with mud, Judge Rabbit didn't want to sit there. He picked a water lily leaf and put it on the crocodile's back before sitting down.

The crocodile looked around with surprise, "Why do you put that leaf on my back?"

The rabbit responded, "Because I am not clean. I don't want to make your back dirty."

The crocodile went across the river and dropped him on the opposite bank. When he was in a safe place, Judge Rabbit said,"Blockhead, where do you expect to find sweet water and sweet mud? Your back is dirty. That's why I put the leaf down to sit on. And then you carried me across the river."

The angry crocodile sat thinking of a way to get revenge while Judge Rabbit went along on his journey.

# សុភាទន្សាយឆ្លងស្ទឹង

នាថ្ងៃដែល ទន្សាយរត់រួចពីកសិករមក ហើយក៏ចង់ឆ្លងស្ទឹង ប៉ុន្តែសុភាទន្សាយតែម្នាក់ឯង ពុំអាចឆ្លង បានទេ ។ ទន្សាយគិតថា "អញនឹងប្រើកិច្ចកលបញ្ឆោតក្រពើ ឲ្យចម្លងអញទៅត្រើយនាយ ។

សុភាទន្សាយរត់ទៅមាត់ស្ទឹង បានឃើញក្បាលក្រពើងើបចេញពីទឹក ក៏ស្រែកហៅថា "អ្ហា! បង ក្រពើ ខ្ញុំឥតស្មៅស៊ីទេ នៅត្រើយខាងអាយនេះ ។ សូមយកអាសារខ្ញុំផង សូមចម្លងខ្ញុំទៅដាក់ ត្រើយនាយ ។ ខ្ញុំស្គាល់កន្លែងមួយ ដែលមានស្មៅផ្អែម ផ្លែផ្អែម និងទឹកផ្អែម ។ បងឯងនឹង ត្រូវការបងមុខជាសប្បាយចិត្តនៅទីនោះ ។

ក្រពើឮដូច្នេះសប្បាយចិត្តហើយឆ្លើយថា "បងទន្សាយឯងអាណិតអាសូរខ្ញុំ សូមបងណែនាំខ្ញុំឲ្យបានទៅ ដល់កន្លែងដែលមានទឹកផ្អែម និងផ្លែផ្អែម ខ្ញុំត្រេកអរណាស់ ខ្ញុំនឹងមិនភ្លេចគុណបងទេ" ។ សុភាទន្សាយ ឆ្លើយថា "ដូច្នេះ ឡើងទៅទីនោះ" ។ ក្រពើអញ្ជើញបងទន្សាយឲ្យអង្គុយលើខ្នងខ្លួន ។ កាលបើឃើញស្បែកក្រពើគ្រោតគ្រាត ប្រឡាក់ភក់ ទន្សាយមិនហ៊ានអង្គុយលើ ក៏បេះស្លឹក ប្រពិតក្រាលអង្គុយលើខ្នងក្រពើនោះ ។ ក្រពើឃើញហើយក៏សួរដោយឆ្ងល់ថា "ម៉េចក៏បងទន្សាយ ឯង ក្រាលស្លឹកឈើលើខ្នងខ្ញុំដូច្នេះ" សុភាទន្សាយឆ្លើយថា "ព្រោះតែខ្ញុំមិនសូវស្អាត ខ្ញុំមិនចង់ ធ្វើខ្នងបងក្រពើឯង ឲ្យប្រឡាក់" ។

ក្រពើហែលឆ្លងស្ទឹង ហើយដាក់ទន្សាយឯត្រើយនាយ ។ លុះដល់ត្រើយដីគោកហើយ សុភាទន្សាយ និយាយថា "នែ! បងខ្លៅ បងឯងជឿថាមានទឹកផ្អែម ផ្លែផ្អែមមែនឬ ខ្នងបងឯងគ្រើមណាស់ ហេតុនោះខ្ញុំក្រាលស្លឹក ហើយបានហ៊ានអង្គុយលើ រួចបងបានចម្លងខ្ញុំមកដល់ទីនេះ ។

ក្រពើខឹងណាស់ សំកាំងគិតរកមធ្យោបាយសងសឹកវិញ ឯទន្សាយបន្តដំណើរទៅមុខទៀត ។

# JUDGE RABBIT AND THE OLD LADY

One day, Judge Rabbit went looking for food in the forest, but he couldn't find anything to eat. He was very hungry and very thirsty. He decided to come out of the forest. Well, he saw an old lady who was carrying a big basket of vegetables and fruit on her head. Judge Rabbit wanted to eat the bananas she was carrying, so he ran to the middle of the path and lay down pretending to be dead.

The old lady came by and saw the dead rabbit. She picked him up and said, "What a lucky day! This rabbit just died. I'll eat it, and I can save some money on my lunch today." Then she put the rabbit in her basket and continued on her way.

Judge Rabbit rose up in the basket, crossed his legs and ate the bananas. When the old lady neared the village, Judge Rabbit shook the basket. The old lady was startled. She put the basket down, and Judge Rabbit jumped out quickly without even saying good-bye.

The old lady was very cross with the Rabbit. She ran after him, but she couldn't catch him. She got tired and came back for her basket. Judge Rabbit was running so fast he did not see a well in front of him, so he fell into it. Fortunately the well was dry, but it was deep enough that Judge Rabbit could not jump out. What could he do?

Bad deeds give bad results; good deeds give good results.

## សុភាទន្សាយ និង ដូនចាស់

ថ្ងៃមួយ សុភាទន្សាយស្វែងរកអាហារក្នុងព្រៃ តែរកអ្វីមិនបានស៊ីសោះ ពោះកាន់តែឃ្លាន ក៏សំរេចចិត្តចេញពីព្រៃ ទៅរកចំណីអាហារតាមផ្លូវវិញ ហើយបានជួបដូនចាស់មួយនាក់ ដែលកំពុងទូលកញ្ជើបន្លែ និង ចេក ។ លុះឃើញដូច្នេះ សុភាទន្សាយកំពុងតែឃ្លានស្រាប់ផង ក៏ធ្វើពុតជាដេកស្លាប់នៅលើថ្នល់ ។

នៅពេលដូនចាស់មកដល់ទីនោះ ឃើញទន្សាយស្លាប់ ក៏រើសដាក់កញ្ជើ ហើយនិយាយថា " អី ថ្ងៃនេះមានលាភមែន ទន្សាយនេះទើបនឹងងាប់សោះ អញនឹងយកវាទៅធ្វើម្ហូប ប្រាកដជាបានសំចៃប្រាក់ខ្លះពីទិញម្ហូបអាហារថ្ងៃត្រង់នេះ ។" នឹកដូច្នេះហើយ ដូនចាស់ក៏លើកទន្សាយដាក់ក្នុងកញ្ជើ បន្តដំណើរទៅមុខទៀត ។

និយាយពីសុភាទន្សាយ នៅពេលដូនចាស់បោះវាទៅ លើកញ្ជើ សុភាទន្សាយក្រោកអង្គុយផង អន្ទាក់ខ្លា ហើយក៏ចាប់បកចេកស៊ីមួយម្ដង ៗ ។ ពេលដែលដូនចាស់ដើរជិតដល់ភូមិ សុភាទន្សាយនោះកញ្ជើយាយ ។ ដូនចាស់ភ្ញាក់ព្រើត ក៏ដាក់កញ្ជើចុះ ស្រាប់តែសុភាទន្សាយលោតផ្លោតចេញពីកញ្ជើ ហើយរត់ចូលព្រៃបាត់ ។

ដូនចាស់អាក់អន់ចិត្តនឹងទន្សាយយ៉ាងខ្លាំង ក៏ដេញតាមចាប់ទន្សាយ តែមិនអាចចាប់បាន ។ ដោយអស់កម្លាំងខ្លាំងពេកដូនចាស់ក៏ត្រឡប់មកកញ្ជើវិញ ។ ចំណែកឯសុភាទន្សាយកំពុងតែរត់យ៉ាងលឿន ដោយមិនបានមើលផ្លូវល្អ ក៏ធ្លាក់ទៅក្នុងអណ្ដូង ចំណែកឯអណ្ដូងនោះអស់ទឹក តែអណ្ដូងនោះជ្រៅគួរសមដែរ ដែលធ្វើឲ្យសុភាទន្សាយលោតចេញមិនរួច ។ តើសុភាទន្សាយដោះស្រាយយ៉ាងណា ។

អំពើអាក្រក់ឲ្យផលអាក្រក់
អំពើល្អឲ្យផលល្អ ។

# JUDGE RABBIT, THE TIGER AND THE MEN

A tiger came near the well and saw Judge Rabbit trapped down there. He wanted to eat the rabbit and said, "Well, now, friend! Today is my lucky day; I'll have you for lunch. You will die today."

Judge Rabbit responded, "Oh yeah? Do you think so, friend? The sky is going to collapse, and you'll be crushed. You are going to die right now."

The tiger looked up at the sky. He saw some clouds moving around. He believed in Judge Rabbit's words. He felt frightened and pleaded, "Please, Rabbit, let me come down with you in the well, so the sky won't crush me!! "

Judge Rabbit said, "No, it's not possible. If you come here, you'll eat me!"

The tiger replied, "No, I promise, I won't eat you. Please let me in."

The tiger asked Judge Rabbit so many times, he finally agreed. The tiger jumped down into the well. Judge Rabbit had thought of a way out. He went back and forth and then he turned back to the tiger. He jabbed the tiger's hip several times.

The tiger said, "Don't jab me like that, Rabbit. Otherwise, I'm going to throw you out of the well, and the sky will crush you."

Judge Rabbit didn't care; he kept hitting the tiger until the poor tiger couldn't take it anymore. He got so angry he caught the rabbit and threw him out of the well.

Once Judge Rabbit was up there free, he cried, "Oh! Hey! A tiger fell in the well! A tiger fell in the well!"

Many men, who were making haystacks in the field nearby, heard that and ran up to the well. When they saw the tiger inside the well, they began to fight with the hayforks. In the meantime, Judge Rabbit stole a torch, which the men had to light their way home. He lit it and put it on top of a haystack and cried, "Help! Help! The haystacks are on fire!!"

The men turned back and saw the flame on top of the haystack. They stopped fighting the tiger and hurried back to put out the fire. The tiger was already hurt, so when he jumped out of the well, he ran off into the forest without trying to bother either the men or Judge Rabbit.

## សុភាទន្សាយ ខ្លា និង អ្នកស្រុក

ពេលនោះខ្លាមួយបានដើរមកក្បែរអណ្ដូង ក៏បានឃើញសុភាទន្សាយធ្លាក់អណ្ដូង ។ វាចង់ស៊ីសុភាទន្សាយ ហើយនិយាយថា " ល្អ ភ្ញើន ថ្ងៃនេះជាថ្ងៃល្អ អញបានទន្សាយឯងធ្វើជាអាហារ ថ្ងៃនេះទន្សាយឯងនឹងងាប់ ។ សុភាទន្សាយឆ្លើយតបវិញថា " អូអញ្ចឹង អ្នកឯងគិតអញ្ចឹង ឬ ភ្ញើន ? មេឃជិតរលំសង្កត់ រូបខ្លួនអ្នកឯងនឹងត្រូវមេឃកិន អ្នកឯងនឹងងាប់ឥឡូវនេះហើយ " ។

ខ្លាងើបមើលទៅលើមេឃ ។ វាឃើញពពករសាត់ទៅមក វាក៏ជឿពាក្យសុភាទន្សាយ ។ ខ្លាភ័យណាស់ក៏អង្វរថា : " បងទន្សាយ បងមេត្តានាំខ្ញុំចុះទៅក្នុងអណ្ដូងផង កុំឲ្យមេឃសង្កត់ខ្ញុំ ។ " សុភាទន្សាយឆ្លើយថា : " មិនបានទេ តែបងឯងចុះមកមុខតែស៊ីខ្ញុំហើយ " ខ្លាតបថា " តែបងទន្សាយ ខ្ញុំសន្យាថាមិនស៊ីបងឯងទេ អាណិតតែនាំខ្ញុំចុះទៅផង ។ ខ្លាអង្វរសុភាទន្សាយច្រើនដង ទើបសុភាទន្សាយសុខចិត្ត ខ្លាក៏លោតចុះទៅក្នុងអណ្ដូង ។ សុភាទន្សាយនឹកឃើញមធ្យោបាយមួយ ដើម្បីលោតចេញពីអណ្ដូង ។ វាដើរចុះ ដើរឡើងរួចងាកមកចាក់ក្រឡេកខ្លា ។ ខ្លាហាមថា " តែបងទន្សាយកុំចាក់ក្រឡេកខ្ញុំ ប្រយ័ត្នខ្ញុំច្រះបងឯងឲ្យមេឃសង្កត់ " ។ សុភាទន្សាយក៏នៅតែចាក់ក្រឡេកខ្លា កាន់តែខ្លាំងឡើងរហូតដល់ខ្លាទ្រាំមិនបាន ក៏ចាប់ទន្សាយច្រះឡើងទៅលើ ។

ពេលសុភាទន្សាយរួចខ្លួនក៏ស្រែកថា " ខ្លាធ្លាក់អណ្ដូង ខ្លាធ្លាក់អណ្ដូង " ។ អ្នកស្រុកជាច្រើនដែលកំពង់រៀបចំបើងនៅក្នុងស្រែជិតនោះ ឮដូច្នោះក៏នាំគ្នារត់ទៅមើល ។ លុះឃើញខ្លានៅក្នុងអណ្ដូង ក៏ព្រួតគ្នាវាយនឹងរនាស់ ។ ក្នុងពេលជាមួយគ្នានោះ សុភាទន្សាយក៏ទៅលួចចន្លុះ រួចដុតយកទៅដាក់ នៅលើកំពូលគំនរចំបើង ហើយស្រែកថា ជួយផង ជួយផង ភ្លើងឆេះគំនរចំបើង ភ្លើងឆេះគំនរចំបើង ។ អ្នកស្រុកឈប់វាយខ្លា ងើបមកមើលគំនរចំបើងក្នុងស្រែ លុះឃើញអណ្ដាតភ្លើងឆេះនៅលើគំនរចំបើង នាំគ្នារត់ទៅពន្លត់ភ្លើង ។ ខ្លាត្រូវរបួស លោតចេញពីអណ្ដូងចូលទៅក្នុងព្រៃយកតែរួចខ្លួន ដោយលែងរបៀតរបៀនអ្នកស្រុក និងទន្សាយ ទៀត ។

## HOW JUDGE RABBIT MADE FRIENDS WITH THE GOAT

One day, Judge Rabbit went to the farmer's garden for some bananas. The farmer was angry to see his bananas disappear, so he set a trap. Judge Rabbit was caught. He was afraid because he knew that the farmer was going to kill him. When Judge Rabbit heard the farmer coming near, he pretended to be dead. The farmer picked him up and said,"Now, Rabbit, are you going to steal bananas again? You cannot eat the bananas from my garden anymore!"

The farmer brought the rabbit home and told his wife to prepare it for dinner. His wife put the rabbit in the corner of the house and went for the other ingredients. Judge Rabbit jumped up and ran fast, but the farmer saw him. He threw a spear to kill the rabbit and hit the rabbit's leg. Judge Rabbit continued to run toward the big bushes. The rabbit's leg was hurt, however, and he couldn't run all the way.

Near the bushes, there was an old, blind goat, Judge Rabbit saw him and asked, "Dear Goat, my leg is broken, and I cannot walk. Your eyes are blind, and you can't see anything. So we could work together. You have your solid legs, and my eyes are good. If you have me sit on your back, I can direct you wherever we can easily find food."

The goat accepted, and the two friends lived happily together. Unity is a way for happiness and prosperity....

# សុភាទន្សាយ និងពពែ

ថ្ងៃមួយសុភាទន្សាយដើរចូលទៅក្នុងចំការចេក ដើម្បីរកអាហារ ។ ម្ចាស់ចំការខឹងនឹងបាត់ចេកច្រើនផងពេក ក៏ដាក់អន្ទាក់ក្នុងចំការនោះ ។ លុះពេលដែលចូលទៅក្នុងចំការ សុភាទន្សាយក៏ជាប់អន្ទាក់នោះទៅ ។ សុភាទន្សាយក៏ភ័យណាស់ព្រោះដឹងថាម្ចាស់ចំការនឹងសម្លាប់ខ្លួនជាមិនខាន ។ ពេលដឹងថាម្ចាស់ចំការដើរមកដល់ ក៏ធ្វើពុតជាងាប់ ។ ម្ចាស់ចំការដោះទន្សាយចេញពីអន្ទាក់ រួចនិយាយម្នាញ់ម្នាយថា " ទម៉ចទន្សាយឯងតូចកញ្ចូចចេកស៊ីណាស់ ត្រូវស៊ីទៀតទៅ " ។

ម្ចាស់ចំការយួរទន្សាយទៅផ្ទះ ហើយប្រគល់ឱ្យប្រពន្ធធ្វើម្ហូប ។ ប្រពន្ធគាត់ចាប់សុភាទន្សាយទៅគៀនជញ្ជាំង រួចដើរទៅរកគ្រឿងផ្សំទៀត ។ សុភាទន្សាយឆ្លៀតឱកាសនោះ ចេញពីផ្ទះយ៉ាងលឿន តែទទួលម្ចាស់ចំការឃើញទាន់ក៏ទាញយកដំបងគប់ត្រូវជើងទន្សាយ ។ ទន្សាយបាក់ជើង ប៉ុន្តែនៅតែខំរត់រហូតដល់កន្លែងព្រៃ នៅកន្លែងនោះមានពពែខ្វាក់មួយ សុភាទន្សាយឃើញហើយ និយាយថា : " បងពពែខ្ញុំបាក់ជើង ចំណែកបងឯងវិញខ្វាក់ភ្នែក ។ ខ្ញុំមានភ្នែកល្អ បងឯងមានជើងមាំដូច្នេះបើសិនណាជាយើង រកស៊ីជាមួយគ្នាប្រហែលជាស្រួល បងឯងឱ្យខ្ញុំជិះលើខ្នង ចំណែកខ្ញុំជាអ្នកប្រាប់ផ្លូវ ដូច្នេះយើងអាចដើររកស៊ីស្រួលទាំងពីរនាក់ ។ ពពែយល់ព្រម ទន្សាយនិងពពែក៏នាំគ្នាដើររកស៊ីយ៉ាងសុខសាន្តនៅក្នុងព្រៃនោះទៅ ។

**សាមគ្គីជាមធ្យោបាយនាំឱ្យបានសុខចំរើន**

## HOW JUDGE RABBIT HELPED HIS FRIEND THE GOAT

One day, a tiger, looking for food in the forest, saw both friends: Judge Rabbit and the goat. The tiger wanted to eat the goat. The rabbit knew it and said to the goat, "Now, look out, my friend! The tiger wants to eat you."

The goat was frightened and asked for help. Judge Rabbit said, "Be quiet! Let me do it."

Then he pretended to talk to the goat. He spoke fearlessly, "I killed five tigers this morning and peeled their skins to make a carpet. I need one more piece to finish my work. Do you know where I can find another one?"

When the tiger heard that, he was frightened and escaped into the forest. A monkey, who had seen the tiger running, came down from the tree and asked him, "Brother Tiger, why are you running so fast?"

The tiger responded, "I saw an animal! I don't know what it was. He was very small, with four feet and two eyes like other animals, but he said, 'I killed five tigers this morning and peeled their skins to make a carpet. I need one more piece to finish my work,' and he's going to find another one. You see, if he had seen me, he would have killed me."

The monkey said, "Let's go and see that wicked animal!"

The tiger said, "No, I dare not go!"

The monkey replied, "Brother Tiger, there is nothing to be afraid of. Let me do it for you. I'm going to catch that bad animal and put it in a cage for you."

The tiger cried,"Monkey!! You forget something. That animal will kill me!"

The monkey said, "Since you are so afraid, let's tie our tails together." Then they tied their tails together and went to meet Judge Rabbit and the goat.

## សុភាទន្សាយជួយជីវិតពពែ

ថ្ងៃមួយខ្លាកំពុងដើររកស៊ីនៅក្នុងព្រៃ ក៏បានឃើញសុភាទន្សាយ និងពពែ ។ ខ្លានឹកចង់ស៊ីពពែ ។ លុះសុភាទន្សាយដឹងដូច្នោះ ក៏និយាយទៅពពែ ថា " នែ បងពពែខ្លាវាចង់ស៊ីបង ឯង" ។ ពពែបានឮដូច្នោះភ័យណាស់ក៏អង្វរឱ្យទន្សាយជួយ ។ សុភាទន្សាយឆ្លើយថា " កុំព្រួយ បងនៅឲ្យស្ងៀមចាំខ្ញុំជួយ ។" ថាដូច្នោះហើយ សុភាទន្សាយក៏ធ្វើជានិយាយខ្លាំងៗ ទៅរកពពែថា " ព្រឹកមិញខ្ញុំសម្លាប់ខ្លាបានប្រាំ បកយកស្បែកធ្វើជាកំរាលផ្ទះ ឥឡូវនេះខ្វះមួយបំណែកទៀត បងឯងដឹងទេ តើនៅកន្លែងណាខ្ញុំអាចបានមួយបំណែកទៀត ? ។"

ឮដូច្នោះ ខ្លាភ័យណាស់ ក៏រត់ចូលព្រៃយ៉ាងលឿន ទៅជួបនឹងស្វា ។ ស្វាសួរខ្លាថា " នែបងខ្លា បងឯងរត់ទៅណា លឿនម្ល៉េះ ? ។" ខ្លាឆ្លើយថា" ខ្ញុំឃើញសត្វមួយនោះ តែខ្ញុំមិនស្គាល់វាជាសត្វអ្វីទេ វាជាសត្វតូចណាស់ មានជើងបួន និងភ្នែកពីរដូចយើងរាល់គ្នាដែរ វាបាននិយាយថា " ព្រឹកមិញខ្ញុំបានសម្លាប់ខ្លា ប្រាំ ហើយបានបកយកស្បែកទៅធ្វើកំរាលផ្ទះ ឥឡូវនេះខ្ញុំត្រូវការមួយបន្ទះទៀត ដើម្បីបំពេញឲ្យបានជិតល្អ តើបងឯងមានឃើញខ្លានៅកន្លែងណាដែរ ?។" បងឯងឃើញទេ បើវាឃើញខ្ញុំ នោះវានឹងសម្លាប់ខ្ញុំហើយ ។" ស្វានិយាយថា " មក ទៅមើលសត្វចំឡែងនោះបន្តិចមើល ។" ខ្លានិយាយថា " ទេ ខ្ញុំមិនហ៊ានទៅទេ " ខ្លាក៏បន្ថែមទៀតថា " បងខ្លាឯងកុំភ័យ ចាំខ្ញុំចាត់ការឲ្យ ខ្ញុំនឹងទៅចាប់សត្វចំឡែងនោះដាក់ទ្រុងឲ្យបងឯង ។" ខ្លាស្រែកថា " នែបងស្វា បងស្វាឯងភ្លេចហើយ ថាវាហ៊ានសម្លាប់ខ្ញុំ !! " ឮដូច្នោះស្វាក៏តបទៅវិញ " បើបងឯងខ្លាចខ្លាំង ៗ មកយើងចងកន្ទុយឲ្យជាប់គ្នាទៅ ។" ខ្លាក៏យល់ព្រមព្រោះស្រួលចងកន្ទុយជាមួយស្វា ហើយនាំគ្នាទៅជួបសុភាទន្សាយ និង ពពែ ។

When the rabbit saw the tiger and the monkey with their tails tied together, he said to them,"Eh! Monkey, you fled from me once, and I couldn't find you! And now, you came back and brought me that skinny tiger. Alright, that's good. I'm going to take his skin."

The tiger's body became shaky. He said to the monkey, "Let's run fast. Monkey!! We can't stay here anymore. If you stay here, you are dead, too!"

With that, he jumped up and jolted the monkey along behind him. The poor monkey died. When the tiger stopped running, he turned back to the monkey whose mouth hung open in death. The tiger became angry with the monkey and said, "Oh! Silly Monkey! Why are you laughing while I am frightened to death."

He didn't know the monkey was dead.

A friend in need is a friend indeed.

នៅពេលយុភាទន្សាយមើលឃើញ ខ្លា និងស្វាចងកន្ទុយគ្នា ដើរចូលមក ក៏ពោលថា "ហែបងស្វា ស្វាឯងបានរត់រួចពីកណ្ដាប់ដៃខ្ញុំម្ដងហើយ ខ្ញុំរកតែមុខ ប៉ុន្តែមិនដែលបានជួបនឹងស្វាឯងសោះ ឥឡូវឯងមកហើយ ព្រមទាំងយកអាខ្លាស្គមមកឲ្យខ្ញុំផង ល្អណាស់ ខ្ញុំនឹងពន្លះយកស្បែកវា ។" លុះឮដូច្នេះខ្លាភ័យញ័រខ្លួន ហើយនិយាយទៅកាន់ស្វាថា " រត់ឲ្យឆាប់បង ស្វា យើងមិនអាចនៅទីនេះបានទៀតទេ ប្រសិនបើយើងមិនរត់ យើងនឹងស្លាប់មិនខាន ។ និយាយរួច ខ្លាក៏រត់ប៉ប្រះថយក្រោយ នាំទាំងស្វាទៅជាមួយផង ។ ចំណែកស្វាវិញ ដល់ត្រូវខ្លាបោកខ្ទាំងពេក ក៏ស្លាប់ហាមាត់ស្មេញ ។ មួយសន្ទុះក្រោយមក ខ្លាហត់ពេកក៏ឈប់រត់ រួចងាកមកមើលស្វា ។ លុះឃើញស្វាងាប់ញេញញ ធ្មេញស្មេញ ស្មានថាស្វាសើចចំអកឲ្យខ្លួន ក៏ខឹងហើយនិយាយទៅកាន់ស្វាថា " "នែ៎ អាស្វាចង្រៃ យើងភ័យស្ទើរស្លាប់ វាបែរជាសើចយ៉ាងស្រួល ។" -

> មិត្តល្អជាមិត្តដែលដឹងទុក្ខធុរៈគ្នាក្នុងគ្រាក្រ
>
> សេពប្រាជ្ញបានសុខ សេពពាលបានទុក្ខ

## JUDGE RABBIT AND THE SNAIL RACE

One day, Judge Rabbit went for a drink from a big lake where there were many watersnails. Seeing Judge Rabbit arrive at the lake, one of the snails approached and asked, "Hey! Rabbit, I heard someone say that you run very fast. Is that true or not?"

Judge Rabbit proudly responded, "That's true. Of all the animals who have legs, none of them run as fast as I do. I am the fastest one of all."

The snail gave a look to his friends. They wanted to play a trick on Judge Rabbit. Turning back to the rabbit, he said, "If you, Rabbit, are the fastest animal of all, would you like to race me? I'll make a bet. If I win, you mustn't drink this water, but if you win, I will leave the lake."

Judge Rabbit said in surprise, "What a silly idea you have! It is a big mistake to dare doing that."

The snail answered, "Are you afraid of me? Let's run around the lake, and we will see!"

The rabbit said, "Run wherever you like; I am not afraid of you."

The snail suggested, "We will meet here tomorrow at this time."

The snail gathered his friends together and said, "Friends, you all know that we can't even run as fast as the caterpillar, let alone the rabbit, but listen carefully. You all disperse along the shore of the lake. When the rabbit calls, 'Snail, where are you?' the one of you in front of him must answer, 'I'm here.'"

The snails spread all around the big lake. When the time drew near, Judge Rabbit appeared. The snail said, "What are we waiting for? Are you afraid?"

## សុភាទន្សាយ និង ខ្យង

ថ្ងៃមួយ សុភាទន្សាយទៅរកផឹកទឹកនៅក្នុងបឹងធំ ហើយបានជួបខ្យងនៅទីនោះ ។ លុះឃើញសុភាទន្សាយមកដល់ ខ្យងចូលទៅជិតហើយស្រែកសួរថា "ថែន បងទន្សាយ ខ្ញុំឮគេថាបងឯងរត់លឿនណាស់ តើមែនទេ សុភាទន្សាយតបទៅខ្យងវិញយ៉ាងក្រអឺតថា "មែនហើយ បណ្ដាសត្វមានជើងទាំងអស់ គ្មាននរណារត់លឿនដូចខ្ញុំទេ គឺខ្ញុំនេះហើយជាអ្នករត់លឿនជាងគេបំផុត ។" ខ្យងខ្សួយញញ្ញាទៅមិត្រភក្តិ ព្រោះចង់ញុកសុភាទន្សាយ រួចបែរមកមើលសុភាទន្សាយក៏សួរថា "បើបងទន្សាយឯងរត់លឿនជាងគេបង្អស់មែន តើបងឯងចង់រត់ប្រណាំងនឹងខ្ញុំទេ ។ យើងនឹងភ្នាល់គ្នា បើខ្ញុំឈ្នះ បងទន្សាយឯងមិនត្រូវមកផឹកទឹកបឹងនេះទេ តែបើបងឯងឈ្នះខ្ញុំវិញ ខ្ញុំនឹងដើរចេញពីបឹងនេះ ។ សុភាទន្សាយនិយាយទាំងឆ្ងល់ថា បងខ្យងឯងឆ្កួតទេ ឬ? នេះជាកំហុសមួយធំណាស់ ប្រសិនបើបងឯងហ៊ានភ្នាល់ដូច្នេះមែន ។ ខ្យងក៏ឆ្លើយថា បងទន្សាយឯងខ្លាចខ្ញុំ ឬ ? មក...យើងរត់ប្រណាំងគ្នាជុំវិញបឹងនេះ យើងនឹងដឹងជាមិនខាន ។ សុភាទន្សាយតបថា "រត់ណាក៏បានដែរឲ្យតែបងខ្យងឯងចូលចិត្ត ខ្ញុំមិនខ្លាចបងខ្យងឯងទេ "។ ខ្យងខ្សោបល់ថា " ចាំតែយើងជួបគ្នាកន្លែងនេះ ពេលថ្ងៃរសៀលនៅថ្ងៃស្អែក"។ ខ្យងប្រមូលមិត្តភក្តិទាំងអស់របស់ខ្លួនមកជួបជុំគ្នា ហើយ និយាយថា " ភឿន! អ្នកឯងទាំងអស់គ្នាដឹងស្រាប់ហើយថា យើងមិនអាចរត់ឈ្នះសូម្បីដង្កូវផង និយាយថ្វីដល់ទៅទន្សាយ ។ ប៉ុន្តែ ចូរអ្នកទាំងអស់គ្នាស្ដាប់ខ្ញុំឲ្យបាន ត្រូវយើងរាយប្រដាក់គ្នាឲ្យបានជុំវិញបឹង បើកាលណាគ្នាយើងទាំងអស់គ្នា ឮបងសុភាទន្សាយស្រែកហៅ 'បងខ្យងនៅឯណា' អ្នកណាមួយនៅខាងមុខបងទន្សាយត្រូវឆ្លើយថា ខ្ញុំនៅឯណេះ"។

ខ្យងរាយគ្នាព័ទ្ធជុំវិញបឹង លុះដិតដល់ពេលប្រណាំង ទន្សាយក៏មកដល់ ។ ខ្យងសួរទន្សាយថា "យើងរង់ចាំអ្វីទៀត បងឯងខ្លាចខ្ញុំ ឬ ? "

Judge Rabbit did not know that the snails would play a trick on him. He crossly answered, "Who in the world would be afraid of you, Snail."

"Then, let's go," the snail replied.

They began to run. A moment later, Judge Rabbit turned around looking for the snail, and then he called, "Snail, where are you?"

The snail in front of him answered, "Here!"

Judge Rabbit was surprised. He sped up again and called once more, "Snail, where are you?"

One of them answered, "I'm here!"

Judge Rabbit pushed all his effort, and as he ran around the lake, he cried out loudly, "Snail, where are you?"

Each time, the next snail would answer, "I'm here!"

Judge Rabbit continued running until he almost lost his breath. Finally, he had to stop. When he stopped, the snail who was in front of him said, "Now, Brother Rabbit, you mustn't come to this water because you lost your bet."

Judge Rabbit, losing his race, was very ashamed. He retired and promised not to come to the lake anymore.

Practical knowledge outsmarted Judge Rabbit's intelligence.

លោកទន្សាយមិនបានដឹងថាខ្យងប្រុងប្រៀបខ្លួនទេ ក៏ឆ្លើយទាំងខឹងទៅខ្យងវិញ " នរណាខ្លាចបងខ្យងឯងក្នុងលោកនេះ ! "

សត្វទាំងពីរក៏ចាប់ផ្តើមប្រណាំងគ្នា ។ មួយខណៈនោះមក លោកទន្សាយងាកមករកខ្យង ហើយក៏ហៅ " បងខ្យង បងឯងនៅណា ? " ខ្យងមួយនៅខាងមុខទន្សាយឆ្លើយថា " ខ្ញុំនៅឯណេះ " ទន្សាយខំប្រឹងរត់យ៉ាងអស់ទំហឹងជុំវិញបឹង ហើយស្រែកសួរទៅខ្យងយ៉ាងខ្លាំងថា " បងខ្យង បងឯងនៅណា ?" រាល់ដងនៅពេលទន្សាយសួរ ខ្យង តែងឆ្លើយ " ខ្ញុំនៅឯណេះ " ។

ទន្សាយខំប្រឹងរត់ដល់ពេលយប់ ហួតហត់ស្ទើរផុតដង្ហើម ទីបំផុតលោកទន្សាយក៏ឈប់រត់ ព្រោះហត់ខ្លាំងពេក ។ ពេលដែលទន្សាយឈប់រត់ខ្យងនៅខាងមុខពោលថា " បងលោកទន្សាយ បងឯងត្រូវឈប់មកផឹកទឹកបឹងនេះតទៅទៀត ព្រោះបងឯងភ្លាត់ចាញ់ខ្ញុំ " ។
លោកទន្សាយរត់ចាញ់ខ្យង នឹកអៀនខ្មាសក្រៃលែង ហើយលែងហ៊ានអួតអាងតទៅទៀត ដោយសន្យាថានឹងមិនមកផឹកទឹកបឹងនេះទៀតទេ ។

ចេះឯង ឲ្យក្រែងចេះគេ

## HOW JUDGE RABBIT SAVED MEN FROM THE TIGER

One day, four traveling salesmen went across the big forest. They were very tired, so they decided to sleep in the forest. The decision was made to protect themselves during the night. One man said,"We must take precautions in order not to be eaten by the tiger. Let's sleep with all of our feet together. Then the tiger will be confused, so he won't eat us."

Then the men lay down with their feet touching, heads pointed to all four directions. Then covered with a white sheet, they went soundly to sleep.

A tiger looking for food saw the four men, but he did not know what they were. He wondered if it was an animal that might harm him. He did not dare come near, but he did not go anywhere either, so he just lay there and stared at them.

The men woke up, and taking a peep around them, knew that the tiger was watching them. They were afraid for their lives.

Judge Rabbit had been watching all of this and decided the men needed his help, so he came and asked the tiger, "Why do you stay still like this?"

The tiger responded, "You see, Rabbit, this thing is very strange. I want to know what it is! Do you know what it is?"

The Rabbit said, "I don't either, but I have an idea. Let's call all the animals living around here to come and see it in hopes that someone might know what it is."

The tiger agreed, so all the wild animals including the elephants came together in a big crowd. After much discussion, they decided none of them had ever seen it before. So Judge Rabbit told all of them to stand back from the strange animal. He himself stepped slowly to the men. When he was near them, he stopped as if scared. Then he ran back and jumped over the elephant's back crying out loudly,"Let's run as fast as we can! This animal will eat us all!!"

Hearing this, all the animals roared and ran back. The fastest was the tiger. The men were saved, and they were all very grateful to Judge Rabbit.

## សុភាទន្សាយជួយជីវិតឈ្មួញសំពាយបួននាក់

ថ្ងៃមួយ មានឈ្មួញសំពាយបួននាក់ ធ្វើដំណើរកាត់ព្រៃមួយ ។ លុះដើរបានឆ្ងាយបន្តិចទៅក៏អស់កម្លាំងខ្លាំងពេកមិនអាចបន្តដំណើរទៅមុខទៀតបាន ក៏គិតគ្នារកកន្លែងសំរាក ។ មុននឹងដេកឈ្មួញទាំងបួននាំគ្នាគិតរកមធ្យោបាយយ៉ាងណាការពារកុំឲ្យខ្លាស៊ី ពេលកំពុងដេកលក់ ។ មេឈ្មួញនិយាយថា : យើងត្រូវដេកយកជើងទល់គ្នា បែរក្បាលទៅរកទិសទាំងបួន រួចរកកំណាត់សបិទឲ្យជិត ធ្វើដូចនេះខ្លាវាមិនស្គាល់ វាមិនស៊ីយើងទេ ។ ធ្វើដូច្នោះហើយក៏នាំគ្នាដេកលក់ទៅ ។

ក្រោយបន្តិចមកខ្លាមួយក៏មកដល់កន្លែងនោះ កាលបើប្រទះឃើញឈ្មួញទាំងបួននោះ វានឹកឆ្ងល់យ៉ាងខ្លាំង ដោយមិនស្គាល់ថាជាសត្វអ្វី វាមិនហ៊ានទៅជិតព្រោះខ្លាច តែវាក៏មិនទៅណាដែរ ក៏ក្រាបឃ្លាំមើលឡើងទៅរកឈ្មួញទាំងបួន ។ ឈ្មួញទាំងបួនដឹងខ្លួនឡើងរួចលបលួចមើលទៅក្រៅ ពេលឃើញថាខ្លានៅក្បែរខ្លួន ក៏ភ័យណាស់នាំគ្នាប្រឹងដេកស្ងៀម ឡើងរឹងខ្លួន ។

សុភាទន្សាយនៅក្បែរនោះបានឃើញរឿងនោះតាំងពីដើមដល់ចប់ នឹកអាណិតឈ្មួញទាំងនោះ នឹករកល្បិចដើម្បីជួយរំដោះឈ្មួញទាំងនោះ ។ រួចចេញពីចម្ងាយស្រែកសួរទៅខ្លាថា : "តើបងខ្លា បងឯងដេកស្ងៀមធ្វើអ្វីនៅទីនេះ ខ្លាឆ្លើយថា "បងឯងឃើញសត្វនេះទេ" ខ្ញុំមិនស្គាល់វាសោះ បងឯងស្គាល់វាទេ សុភាទន្សាយឆ្លើយថា "ខ្ញុំមិនស្គាល់ទេ តែខ្ញុំមានយោបល់មួយ យើងគិតប្រមូលគ្នាយើងទាំងអស់គ្នាមកមើល ក្នុងចំណោមនោះគង់មាននរណាម្នាក់ស្គាល់សត្វនេះមិនខាន" ។ ខ្លាយល់ព្រមក៏តាំងប្រកូកហៅសត្វដទៃទៀត ដែលនៅជិតខាងនោះឲ្យមកជួបជុំគ្នា ។ សុភាទន្សាយបង្គាប់ឲ្យសត្វធំៗ អស់នោះឈរមួយកន្លែងរួចសួររកអ្នកណាដែលស្គាល់សត្វនោះ ។ លុះដឹងថាគ្មាននរណាម្នាក់ស្គាល់ទេ សុភាទន្សាយក៏ធ្វើជាសម្រេចចិត្ត ដើរយឺតៗ ចូលទៅមើលសត្វនោះ ។ នៅពេលជិតដល់ក៏ប្រញាប់រត់យ៉ាងលឿន លោតទៅលើខ្នងដំរី រួចស្រែកប្រកូកយ៉ាងខ្លាំងថា "ថយក្រោយពួកយើងនាំគ្នារត់ឲ្យលឿន សត្វនេះកាចណាស់ វានឹងខាំស៊ីក្បាលយើងរាល់គ្នាឥឡូវហើយ" ។

សត្វទាំងអស់ឮដូច្នោះភ័យខ្លាំងណាស់ នាំគ្នាបែរក្រោយរត់យ៉ាងលឿន យកតែព្រួសកាយខ្លួន រត់លឿនជាងគេគឺសត្វខ្លា ។ ឈ្មួញទាំងបួននាក់រួចខ្លួនពីស្លាប់ នឹកអរគុណសុភាទន្សាយ ។

## HOW JUDGE RABBIT ESCAPED ONCE MORE FROM THE TIGER

The tiger was very angry with Judge Rabbit because Judge Rabbit had fooled and tricked him so many times. He thought to himself,"I'm going to find that Rabbit, and I will eat him."

Judge Rabbit sped up very fast when he saw the tiger looking for him. The tiger gave chase right behind him. Judge Rabbit tried to find somewhere to hide, but there was nowhere except the line of bamboo trees. He was very tired, but looking up at the bamboo tree, he saw a big wasp nest and got an idea.

He climbed up and picked a bunch of bamboo leaves. Then he carefully filled the hole in the wasps' nest preventing the wasps from coming out. When the wasps couldn't leave the nest, they began to fly around angrily inside. The noise coming out of the nest sounded just like someone playing a Chinese drum, "Moung! Moung! Moung!"

Arriving at the bamboo tree, the tiger said, "Now, Rabbit, how can you flee from me?"

Then he began to climb up the bamboo tree after the rabbit. Judge Rabbit said, "Don't come up, Tiger. The Angel does not permit anyone to come up here except me whom he ordered to play music for him. Besides, I'm the only one who can please him."

The tiger wanted to please the Angel too, so he dared not continue climbing up. He asked Judge Rabbit, "Brother Rabbit, let me play the music for the Angel, too, so I can please him as you do."

Judge Rabbit said, "If you want to please the Angel, you can come up here, but I have to go over there to play another drum. Don't forget! If you want to play the music very well, you have to be very patient. You must wait until I am away from here. Watch, and when you see me jump, strike the drum hard. That way the sound will please the Angel."

## សុភាទន្សាយរត់ដោះខ្លួនពីខ្លាម្តងទៀត

ខ្លាខឹងនឹងទន្សាយយ៉ាងខ្លាំង ព្រោះទន្សាយបានបោកវាច្រើនដងហើយ ។ ខ្លាគិតថា : " អញនឹងទៅរកចាប់ទន្សាយនេះស៊ីម្តង " ។

សុភាទន្សាយរត់យ៉ាងលឿនទៅពេលដែលឃើញលោកខ្លាដេញតាមវា ។ ខ្លាតាមយ៉ាងប្រកិត ។ ទន្សាយព្យាយាមរកកន្លែងពួន ប៉ុន្តែរកមិនបានល្អ មានតែគុម្ពឬស្សី ។ វាអស់កម្លាំងខ្លាំង តែដល់វាក្រឡេកឃើញសំបុកអំម៉ាល់នៅចុងឬស្សី ក៏មានគំនិតដោះស្រាយមួយ កើតឡើង ។

ទន្សាយឡើងដើមឬស្សី ហើយបេះស្លឹកឬស្សីបានមួយក្តាប់ រួចក៏ចុករន្ធអំម៉ាល់យ៉ាងណែនល្អ មិនឲ្យវាហើរចេញមកក្រៅរួច ។ លុះមិនអាចហើរចេញពីសំបុករួច អំម៉ាល់ក៏ហើរជ្រួលច្របល់យ៉ាងក្តៅក្រហាយខាងក្នុងសំបុកវា ។ សំឡេងស្លាបហើរក្នុងសំបុក ហាក់ដូចជាគេវាយស្គរ ព្រូ ម្ហូង ម្ហូង ម្ហូង ។

លុះមកដល់គុម្ពឬស្សី ខ្លានិយាយថា " នែបងទន្សាយ ឥឡូវបងរត់រួចពីដៃខ្ញុំបានទេ ។ " ហើយខ្លាក៏ឡើងដើមឬស្សី តាមចាប់ទន្សាយស៊ី ។ សុភាទន្សាយស្រែកថា " កុំឡើងមកបងខ្លា ទេវតា មិនអនុញ្ញាតឲ្យអ្នកឯទៀតឡើងមកទីនេះទេ ក្រៅពីខ្ញុំ លោកបង្គាប់ឲ្យខ្ញុំលេងភ្លេងថ្វាយ ។ ម្យ៉ាងទៀតខ្ញុំតែម្នាក់ឯងគត់ ដែលអាចលេងភ្លេងថ្វាយទេវតាឲ្យសប្បាយចិត្តបាន ។

ខ្លាចង់ថ្វាយភ្លេងទេវតាផងដែរ ដូច្នេះខ្លាមិនហ៊ានឡើងតទៅទៀត ក៏សុំសេចក្តីអនុញ្ញាតពីទន្សាយថា : " បងទន្សាយ សូមឲ្យខ្ញុំលេងភ្លេងថ្វាយទេវតា ដើម្បីឲ្យទេវតាស្រឡាញ់ខ្ញុំផង ។ " សុភាទន្សាយឆ្លើយថា : " បើបងខ្លាចង់ឲ្យទេវតាសប្បាយចិត្ត បងឯងអាចឡើងមកបាន ។ ចាំតែណកខ្ញុំត្រូវទៅលេងភ្លេងខាងនោះវិញ ។ តែកុំភ្លេច បើបងឯងចង់លេងភ្លេងឲ្យបានពិរោះ ត្រូវចេះអត់ធ្មត់ ។ រួចត្រូវចាំដល់ខ្ញុំទៅឆ្ងាយពីនេះ ចាំមើលពេលណាឃើញខ្ញុំលោត បងឯងទះឲ្យខ្លាំង ។ ដូច្នេះភ្លេងនឹងពិរោះ ទេវតាក៏មុខតែសប្បាយចិត្ត ។

With that, Judge Rabbit moved down from the tree to let the tiger come up. The tiger followed Judge Rabbit's directions.

When Judge Rabbit was very far away, he jumped up and down. Then he sped through the forest. At the same time, the tiger struck the wasps' nest hard. The nest broke, and thousands of angry wasps flew out. They stung the tiger all over. That made the poor tiger fall out of the bamboo tree and get badly hurt.

អាស្រ័យហេតុនេះសុភាទន្សាយប្រូនចុះពីដើមឫស្សី ខ្លាក៏ឡើងទៅ ។ ខ្លាធ្វើតាមបញ្ជា សុភាទន្សាយទាំងអស់ ។ កាលដែលសុភាទន្សាយនៅឆ្ងាយឃ្មុំគេចរួចខ្លួនហើយ វាក៏លោតចុះ ឡើង រួចរត់យ៉ាងលឿនចូលទៅក្នុងព្រៃ ។ ក្នុងពេលដ៏ដែលនោះ ខ្លាក៏ទះសំបុកឃ្មុំយ៉ាង ខ្លាំង ។ សំបុកឃ្មុំបែកខ្ទេច ។ មេឃ្មុំសីលាហានទាំងហ្វូង ហើរចេញមកក្រៅ ហើយ ទិចខ្លា ។ ដូច្នេះខ្លាក៏ធ្លាក់ពីដើមឫស្សី ហើយត្រូវរបួសយ៉ាងដំណំ ។

## HOW JUDGE RABBIT SAVED A MAN AND PUNISHED A CROCODILE

One day a man rode in a cart across the forest. He met a crocodile who said to him, "Oh, Lord! Please take pity on me. This marsh is dry. Please take me to a deep lake."

The man answered, "How can I take you? You are too big."

The crocodile replied, "Put me in your cart."

The man said, "I can't. You are very big and heavy."

The crocodile pleaded, "Tie me under your cart and ride me to a deep fresh lake."

The man took a big rope and firmly tied the crocodile under his cart, and he continued on his way. Arriving at the lake, he untied and freed the crocodile.

The crocodile said, "I am going to eat you now."

The man asked, "Why do you want to eat me?"

The crocodile replied, "You tied me too tight. It hurt me very much, so I will eat you!"

The man cried, "If you are going to eat me, at least let me go to say,'Good-bye,' to my wife and children."

The crocodile agreed, "Go and come back fast. I will wait for you right here."

The man went away crying. A few minutes later, he saw Judge Rabbit, who asked him, "Why are you crying, Brother?"

The man answered, "Oh! Brother Rabbit! I saved the crocodile's life. He told me to tie him under my cart and direct him to a deep lake. When we arrived at the lake, I untied him and freed him. He said that he was very angry with me because I had tied him too tight, and now he's going to eat me. He just let me come to say, 'Good-bye,' to my family."

Judge Rabbit said, "Let's go and see the crocodile."

## ទន្សាយជួយមនុស្សឲ្យរួចពីក្រពើ ហើយ
## ដាក់ទោសទណ្ឌដល់ក្រពើ

ថ្ងៃមួយបុរសម្នាក់បររទេះកាត់វាលព្រៃ ។ ក៏បានជួបក្រពើមួយ ដែលអង្វរករគាត់ថា "ឱ ព្រះអើយ សូមជួយខ្ញុំផង ថ្លុកនេះរីងទឹកអស់ហើយ សូមជួយខ្ញុំឲ្យបានទៅដល់បឹងមានទឹកជ្រៅផង ។ បុរសនោះឆ្លើយថា "ខ្ញុំមិនអាចជួយបានទេ ព្រោះបងក្រពើឯងធំពេក ។ ក្រពើឆ្លើយថា "ដាក់ខ្ញុំក្នុងរទេះលោកទៅ" បុរសនិយាយថា "ខ្ញុំលើកឯងមិនបានទេ ព្រោះធំពេកផង ធ្ងន់ពេកផង" ។ ក្រពើអង្វរករថា "សូមចងខ្ញុំក្រោមរទេះ រួចដឹកខ្ញុំទៅទំលាក់ក្នុងបឹងថ្លាជ្រៅឲ្យបានផង" ។

បុរសយកខ្សែរមួយចងក្រពើយ៉ាងមាំ នៅក្រោមរទេះគាត់ ហើយបន្តដំណើរទៅមុខទៀត ។ លុះដល់បឹងមួយ គាត់ក៏ស្រាយលែងក្រពើឲ្យរស់នៅក្នុងទឹកនោះ ។ ក្រពើនិយាយថា "ខ្ញុំនឹងស៊ីអ្នកឯងឥឡូវនេះ" ។ បុរសសួរថា "ម្ដេចក៏អ្នកឯងចង់ស៊ីខ្ញុំ" ក្រពើឆ្លើយថា "អ្នកឯងចងខ្ញុំតឹងពេក ខ្ញុំឈឺចង់ដាច់ ដូច្នេះខ្ញុំត្រូវតែស៊ីអ្នកឯង" ។ បុរសស្រែកទ្រហោយំថា "បងក្រពើឯងស៊ីខ្ញុំក៏ស៊ីចុះ តែខ្ញុំសូមទៅលាភរិយានិងបុត្រខ្ញុំសិន" ។ ក្រពើអនុញ្ញាតថា "ទៅហើយត្រឡប់មកវិញយ៉ាងឆាប់ អញចាំឯងនៅត្រង់នេះ" ។ បុរសដើរទៅទាំងយំស្រណោក ពីរ បីវិនាទីក្រោយមក បុរសនោះបានជួបទន្សាយ ។ ក៏សួរថា បង ម្ដេចបងឯងយំខ្លាំងណាស់" បុរសឆ្លើយថា "ឱ បង ទន្សាយអើយ ខ្ញុំបានជួយជីវិតក្រពើ ឲ្យរួចពីសេចក្ដីស្លាប់ ដោយវាប្រាប់ខ្ញុំថា ឲ្យខ្ញុំចងវានៅក្រោមរទេះខ្ញុំ ហើយដឹកវាទៅដល់បឹងមានទឹកជ្រៅ ។ លុះបានដល់បឹងនោះហើយ ខ្ញុំក៏ស្រាយរួចលែងវា ហើយវាបាននិយាយនឹងខ្ញុំថា "វាខឹងនឹងខ្ញុំណាស់ ព្រោះខ្ញុំបានចងវា រឹតវាតឹងពេក ដូច្នេះវាត្រូវតែស៊ីខ្ញុំឥឡូវនេះ តែវាអនុញ្ញាតឲ្យខ្ញុំទៅលាគ្រួសារខ្ញុំសិន ។ សុភាទន្សាយនិយាយថា "ចូរយើងទៅមើលអាក្រពើនោះ" ។

When they arrived at the lake, Judge Rabbit said, "Hello," to the crocodile and asked, "Why do you want to eat this man?"

The crocodile replied, "He tied me too tight; I couldn't even breathe."

The rabbit said, "I want to know how tight it was. Brother Crocodile, come here! We'll test it together."

The crocodile came near them. Judge Rabbit told the man to take the rope and tie the crocodile under the cart as he had done before. Then, Judge Rabbit asked the crocodile, "Did he tie you like this?"

The crocodile responded, "If he had tied me like this, I wouldn't have become angry with him."

Judge Rabbit told the man to squeeze the crocodile once more. "Did he do like this to you?" Judge Rabbit asked the crocodile.

The crocodile responded, "Yes, of course! That's why I got angry!"

Judge Rabbit said to the man, "You see, if you press him like this, he has a reason to be angry with you. Now, what are you waiting for? The crocodile is so strongly tied."

And so the man hit the crocodile in the head and killed him.

This story is to advise you that one who receives help from someone must consider the source of the help.

Note: In Cambodian culture, a person is called "Mr. Crocodile" if he does not appreciate his own ancestors, teachers or helpful friends.

កាលបុរស និងទន្សាយទៅដល់បឹងនោះហើយ សុភាទន្សាយក៏ស្រែកថា "ជំរាបសួរ បងក្រពើ ហើយសួរថា "ម្តេចក៏បងចង់ស៊ីបុរសនេះ" ក្រពើឆ្លើយតបថា "វាចងខ្ញុំតឹងពេក រកតែដកដង្ហើមក៏មិនរួចផង"។ សុភាទន្សាយនិយាយថា "ខ្ញុំចង់ដឹងថាតើចំណងនោះ តឹងប៉ុណ្ណាទៅ អញ្ជើញមកនេះ បងក្រពើ យើងចង់សាកល្បងមើលសិ"។ ក្រពើក៏ដើរទៅជិតអ្នកទាំងពីរ គឺបុរស និងទន្សាយ។ សុភាទន្សាយប្រាប់បុរសឲ្យយកខ្សែទៅចងក្រពើ ភ្ជាប់នៅក្រោមរទេះ ដូចដែលគាត់ចងពីមុន។ ហើយសុភាទន្សាយសួរក្រពើថា "តើគាត់ចងបងឯងអញ្ចឹង ឬ" ក្រពើឆ្លើយថា "បើគាត់ចងខ្ញុំប៉ុណ្ណឹង ខ្ញុំខឹងនឹងគាត់ម្តេចកើត"។ សុភាទន្សាយប្រាប់បុរសឲ្យមួលរិតចំណងក្រពើឲ្យកាន់តែតឹងឡើងទៀត ហើយក៏សួរបងក្រពើថា "គាត់ចងបងឯងតឹងអញ្ចឹង ឬ" ក្រពើឆ្លើយថា "បាទ វាតឹងប៉ុណ្ណឹង អញ្ចឹងបានជាខ្ញុំខឹង"។

សុភាទន្សាយប្រាប់បុរសថា "មើលសិ បងឯងចងវាអញ្ចឹងហើយ វាខឹងនឹងបងវិញ តើបងរង់ចាំអ្វីទៀតផងឡូវនេះ"។ បុរសក៏សំពងក្បាលក្រពើរហូតដល់ស្លាប់។ (រឿងនេះឲ្យនឹកវាទៅដល់អ្នកមាន ឬ អ្នកស្លាប់ ថា បើបានទទួលជំនួយពីអ្នកណាមួយ ត្រូវដឹងគុណគេវិញ។)

វិប្បធម៌សង្គមខ្មែរ ហៅថាក្រពើចំពោះបុគ្គលណាមួយ
អ្នកមិនដឹងគុណ បុព្វការី គ្រូបាធ្យាយ ឬ សប្បុរិមិត្រល្អ
ដែលធ្លាប់បានជួយជីវិតខ្លួនរួចមកហើយ។

## HOW JUDGE RABBIT CAPTURED THE GHOST

Once, there was a man who had just married. His wife was as beautiful as gold. He loved her very much and never left her side.

One day, the King raised troops to go to war. He sent messages to all the men in the country to join the Army. The new husband had to go. He was very, very sad because he did not want to leave his new wife. But there was no way that he could avoid it because he was so afraid of the king. The man and his wife wept together, and he told her to prepare provisions for him to go.

Then morning came, and the man left his wife for the first time since their wedding. He cried all the way. When he reached the crossroad by the big bayon tree, he couldn't go further; he returned home. He did that three times. Finally, the fourth time, he decided he must continue on his way.

Now, the bayon tree was the home of a ghost. The ghost had watched the scene with wonder and followed the man home. When the ghost saw the man's wife, he fell in love with her himself. Knowing that the husband would be away from home for a long time, the ghost transformed himself to look like the husband. He looked so exactly like the man that no one could tell. Then, he went to meet the wife.

Seeing her husband home again, the lady asked, "Why are you back so soon? You told me that you decided to go."

The ghost answered, "The war is over already; the king doesn't need the men anymore."

Having no reason to doubt her husband, the lady was very happy and pleased to have him home as usual.

Finally, when the war was really over, the real husband came back home. He called to his wife. The poor lady was shocked to see another man looking just like her husband. She exclaimed, "This is my husband!" Then she turned back to the ghost and said, "This is my husband, too!"

The lady was in panic and did not know what to do.

## សុភាទន្សាយបោកខ្មោចឲ្យចូលដប

សម័យមួយបុរសម្នាក់ទើបនឹងរៀបការប្រពន្ធថ្មី ៗ ។ នាងនោះមានរូបល្អដូចមាស ។ បុរសជាប្ដីស្រលាញ់ភរិយានោះណាស់ មិនដែលដើរទៅណាឆ្ងាយចោលភរិយាទេឡើយ ។

ថ្ងៃមួយព្រះរាជាបង្កើតទ័ពដើម្បីធ្វើសង្គ្រាម ព្រះអង្គបានជ្រើសរើសទៅគ្រប់ប្រជាពលរដ្ឋក្នុងនគរ ឲ្យនាំគ្នាចូលមកធ្វើទាហាន ។ បុរសនោះព្រួយចិត្តខ្លាំងណាស់ ដោយមិនចង់ទៅណាឆ្ងាយពីប្រពន្ធ ប៉ុន្តែមិនដឹងធ្វើដូចម្ដេច ព្រោះខ្លាចអំណាចស្ដេចក៏នាំគ្នាអង្គុយយំ ទីបំផុតក៏ប្រាប់ប្រពន្ធឲ្យរៀបចំបាយទឹកសំរាប់ធ្វើដំណើរ ។

ព្រឹកឡើងបុរសនោះក៏លាប្រពន្ធចេញទៅ យំផងដើរផងតាមផ្លូវរហូតដល់ដើមពោធិធំមួយ ដែលដុះនៅត្រង់ផ្លូវបំបែក ។ គាត់មិនអាចបន្តដំណើរទៅមុខទៀតបាន ក៏ត្រឡប់មកផ្ទះវិញ ។ បុរសនេះដើរទៅមករបៀបនេះបីដង ដល់លើកទីបួនក៏សម្រេចចិត្តថាត្រូវតែទៅជាដាច់ខាត ។

នៅលើដើមពោធិមានខ្មោចមួយវាបានឃើញបុរសនោះយំ ដើរទៅមកជាច្រើនសារ ឆ្ងល់ណាស់ ក៏តាមបុរសនោះទៅដល់ផ្ទះ, លុះវាបានឃើញប្រពន្ធបុរសនោះ,វាចាប់ចិត្តស្រលាញ់ ។ ដោយដឹងថាបុរសជាប្ដីធ្វើដំណើរចេញទៅឆ្ងាយហើយ ខ្មោច ក៏តែងខ្លួនឲ្យដូចជាបុរសនោះ រួចធ្វើដំណើរទៅជួបប្រពន្ធបុរសនោះ ។

នាងជាប្រពន្ធកាលដែលក្រឡេកឃើញប្ដី ឆាប់ត្រឡប់មកផ្ទះម្ដងទៀតក៏សួរថា " ហេតុអ្វីក៏អ្នកឆាប់ត្រឡប់មកម្ល៉េះ អ្នកបានប្រាប់ខ្ញុំថាម្ដងនេះ ត្រូវតែទៅជាដាច់ខាត " ។ ខ្មោចឆ្លើយថា : " សង្គ្រាមចប់ហើយ ស្ដេចលែងត្រូវការមនុស្សទៀតហើយ " ។

ដោយគ្មានហេតុផលធ្វើឲ្យសង្ស័យនឹងប្ដីសោះ នាងជាភរិយាសប្បាយក្នុងចិត្តណាស់រួចរស់នៅជាមួយគ្នាដូចធម្មតា ។ និយាយពីបុរសជាប្ដីនៅពេលសង្គ្រាមចប់ហើយក៏ត្រឡប់មកផ្ទះវិញ ។ លុះមកដល់ផ្ទះស្រែកហៅប្រពន្ធ ។ នាងជាប្រពន្ធចេញពីផ្ទះ ក្រឡេកឃើញបុរសម្នាក់ទៀត ដូចប្ដីខ្លួនក៏ស្រឡាំងកាំងស្រែកថា " នេះប្ដីខ្ញុំ " ។ រួចងាកមកឃើញខ្មោចក៏និយាយថា " នេះក៏ប្ដីខ្ញុំដែរ "។ នាងប្រពន្ធភ័យតក់ស្លុត ដោយមិនដឹងគិតគូរដូចម្ដេច ។

The ghost asked the man, "Who are you? How dare you say that my wife is yours?"

The man responded, "This is my wife. We were married just a few months ago! I went to war, and now I have come back. Who are you? Why are you saying that my wife is yours?"

The ghost and the man argued for a very long time. Finally, they decided to look for a judge. The judge felt awkward and confused seeing both men looking so alike. He did not know what to do except stare at the lady and ask her, "Which one is your husband?"

The lady felt so ashamed not knowing who her husband was. The real husband was very worried. He decided to find someone to help them.

Judge Rabbit saw the man sobbing as he walked. The rabbit asked, "Why are you crying, Brother? What's the matter with you?"

The man told him all about his sad situation.

Judge Rabbit said, "Well, I'll try to help you. If this case is as I understand it, I think I have a plan which will work."

The man and Judge Rabbit came back to where the others were gathered. He told the man to get him a bottle and a cork. Judge Rabbit placed the bottle on the table and said, "The one of you who can get into the bottle is the real husband. The one who cannot get into it is the fake."

The ghost was very happy. He thought he had won. He quickly shrunk himself into a flea and jumped into the bottle.

Then, Judge Rabbit turned to the real husband and said, "Cork the bottle and quickly throw it into the river. Only ghosts can shrink and get into bottles. You are the real husband."

Naturally, the couple was very, very happy. They lived happily ever after as man and wife, and they were always grateful to Judge Rabbit.

ខ្មោចសួរទៅបុរសនោះថា "អ្នកឯងជាអ្វីនឹង" ហេតុម៉េចបានជា អ្នកឯងហ៊ានថាប្រពន្ធខ្ញុំជាប្រពន្ធអ្នកឯង បុរសនោះឆ្លើយថា "នេះជាប្រពន្ធខ្ញុំ" ។ យើងទើបនឹងរៀបការបានប៉ុន្មានខែណោះ ខ្ញុំទៅច្បាំង ឥឡូវខ្ញុំទើបនឹងត្រឡប់មកវិញ ។ អ្នកឯងជាអ្វី ហេតុម៉េចបានជាអ្នកឯងថាប្រពន្ធខ្ញុំជាប្រពន្ធអ្នកឯង" ។

ខ្មោច និងបុរសនោះឈ្លោះប្រកែកគ្នាយ៉ាងយូរ មិនសុខចិត្តទៀងខ្លួន ក៏សម្រេចចិត្តទៅរកចៅក្រម ។ ចៅក្រមឃើញបុរសពីរនាក់ដូចគ្នាពេក ក៏ស្រឡាំងកាំង មិនដឹងកាត់ដូចម្តេច ក្រៅតែពីងាកមករកនាងប្រពន្ធបុរសនោះ រួចសួរថា "អ្នកណាមួយប្តីអ្នកឯង?" ។ នាងជាភរិយា មានការភាន់ច្រឡំយ៉ាងខ្លាំង ព្រោះមិនដឹងថាអ្នកណាមួយត្រូវជាប្តីខ្លួន ។ បុរសជាប្តីព្រួយចិត្តខ្លាំងណាស់ ទើបដាច់ចិត្តដើររកអ្នកណាមួយ ដែលអាចជួយក្នុងរឿងនេះបាន ។

សុភាទន្សាយបានឃើញបុរសនោះដើរបណ្តើរយំបណ្តើរ ក៏សួរថា : "បងឯងមានរឿងអ្វីបានជាដើរផងយំផងដូច្នេះ ។ បុរសនោះក៏រៀបរាប់រឿងរ៉ាវសព្វគ្រប់ ។ សុភាទន្សាយស្តាប់ហើយឆ្លើយថា : "អញ្ចឹងខ្ញុំនឹងសាកល្បងជួយបងឯងមើល៍ បើសិនណាជារឿងនេះដូចគំនិតដែលខ្ញុំយល់ ខ្ញុំជឿថា ស្រួលការខ្ញុំនឹងសម្រេច" ។ សុភាទន្សាយ និងបុរសនោះក៏នាំគ្នាត្រឡប់មកជួបជុំនៅកន្លែងដដែល ។ សុភាទន្សាយប្រាប់បុរសជាប្តីនោះឱ្យរកដបមួយ និងឆ្នុកមួយមកឱ្យ រួចសុភាទន្សាយយកដបនោះមកដាក់លើតុ ហើយនិយាយថា : "អ្នកណាមួយជាប្តីពិតប្រាកដរបស់នាងនេះ អ្នកនោះអាចចូលក្នុងដបនេះបាន ។ អ្នកណាមួយចូលដបនេះមិនបានជាមនុស្សក្លែងក្លាយ ។" ខ្មោចអរណាស់នឹកក្នុងចិត្តថាខ្លួនឈ្នះជាមិនខាន គិតហើយក៏បង្រួញខ្លួនឱ្យតូចទៅជាថែ រួចរោតចូលក្នុងដបនោះ ។ សុភាទន្សាយប្រាប់ទៅបុរសជាប្តីនោះថា "ចុកឆ្នុកដបនោះឱ្យជិត រួចបោះចោលទៅក្នុងទន្លេភ្លាមទៅ ។ មានតែខ្មោចទេដែលអាចចូលក្នុងដបនេះបាន បងឯងជាប្តីពិតប្រាកដរបស់នាងនេះ ។

គូស្វាមីភរិយាមានសេចក្តីរីករាយយ៉ាងខ្លាំង គេរស់នៅយ៉ាងសុខសាន្តរហូតរៀងទៅ ព្រមទាំងនឹករលឹកដល់គុណសុភាទន្សាយ ដែលបានជួយខ្លួនឱ្យរួចពីទុក្ខព្រួយនោះ ។